បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ២០ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

[illegible]

[illegible]

* * *

[illegible]

# [illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

# មាតិកា

## I - ខុទ្ទកាល័យព្រះមហាក្សត្រ

### ១- ព្រះរាជក្រម

២៨-៥-១៩៩៩ -ព្រះរាជក្រម នស/រកត/០៥៩៩/០៣ ច្បាប់ស្ដីពីការហាមប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ៨៩១

### ២- ព្រះរាជក្រឹត្យ

២០-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/៣៥ តែងតាំងលោកអាចារ្យ ហេង គីមគុណ ជាឧកញ៉ា ទទួលកិច្ចការធម្មការក្នុងបរមរាជវាំង ៨៩៥

២៨-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៥ តែងតាំងឯកឧត្ដម ខូន ផនស៊ីផុន ជាទីប្រឹក្សាផ្ទាល់របស់សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី ៨៩៦

២៨-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៦ តែងតាំងឯកឧត្ដម ម៉ម សារិន, សោម សឿន, គាត ស៊ុនអ៊ី ជាប្រឹក្សាផ្ទាល់របស់សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ៨៩៧

២៨-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៧ តែងតាំងមន្ត្រីដឹកនាំខុទ្ទកាល័យផ្ទាល់របស់សម្ដេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ឯកឧត្ដម ជា សុន, លោកជំទាវ គន្ធាបូរី ម៉ាត់លីរុន ឯកឧត្ដម សុខ ណោ ឯកឧត្ដម ហ៊ុន ទុន្ធា ៨៩៨

២៨-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៨ តែងតាំងលោកឧកញ៉ា ស្រី សូម៉ាឈូ ឯកឧត្ដម តាន់ ឃារីស្ទី ឯកឧត្ដម ចាន់ ចំរើន ឯកឧត្ដម គៀត ទាសនា ឯកឧត្ដម នួន ខេន ឯកឧត្ដម គុជ ស៊ីនិត ជាប្រឹក្សាផ្ទាល់របស់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវន្តមុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភា ៨៩៩

២៩-៥-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៩ តែងតាំងឯកឧត្ដម អ៊ុច គឹមអន ជាតំណាងផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជា អមក្រុមប្រឹក្សាអចិន្ត្រៃយ៍ នៃអង្គការប្រែហ្វង់កូហ្វូនី បន្ថែមលើមុខងារបច្ចុប្បន្ន ៩០០

## II. ព្រឹទ្ធសភា

### សេចក្ដីសំរេច

២៦-៥-១៩៩៩ -សេចក្ដីសំរេចលេខ ០០៩/៥៩៩/ពស.សរ ស្ដីពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ៩០១

## III- ក្រុមប្រឹក្សាធម្មនុញ្ញ

### សេចក្តីសម្រេច


២៧-៥-១៩៩៩ -សេចក្តីសម្រេចលេខ ០៧ កបធ.សសរ.ច ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៩០៤

២៧-៥-១៩៩៩ -សេចក្តីសម្រេចលេខ ០៨ កបធ.សសរ.ច ច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម ៩០៥


## IV.រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ


២៥-៥-១៩៩៩ -អនុក្រឹត្យលេខ ៤៨ អនក្រ.បក កែសម្រួលមាត្រាអនុក្រឹត្យលេខ ៥១ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៩០៦

២៥-៥-១៩៩៩ -អនុក្រឹត្យលេខ ១៥០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩១២

២៥-៥-១៩៩៩ -អនុក្រឹត្យលេខ ១៥១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៩១៣

៣១-៥-១៩៩៩ -អនុក្រឹត្យលេខ ១៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៩១៤


### ២- សេចក្តីសម្រេច


២៦-៥-១៩៩៩ -សេចក្តីសម្រេចលេខ ៤៤ សសរ ស្តីពីការបង្កើតអគ្គបញ្ជាការការពារពិធីកំទេចអាវុធ នៅខេត្តកំពង់ចាម ៩១៥


### ៣- ផែនការណែនាំ


២៦-៥-១៩៩៩ -ផែនការណែនាំលេខ ០៨ ផ.ក.ណ ស្តីពីការចាត់តាំងរៀបចំបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ ក្នុងគំរប់ព្រះជន្ម ៦៣ យាងចូល ៦៤ព្រះវស្សា ៩១៧


## V- ការងារបណ្តាក្រសួង

### ១- ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស


២៤-៥-១៩៩៩ -ប្រកាសលេខ ៤៩៩ ឧក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន ហ្វ៊ិចប្លាមេន (ខេមបូឌា) តំណាងដោយលោក SAU KIM HING សញ្ជាតិម៉ាឡេស៊ី បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ ៩១៨

២៤-៥-១៩៩៩ -ប្រកាសលេខ ៥០៣ ពក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌា អែកនីង គ្រុប តំណាងដោយលោក YANG ZHOAFU សញ្ជាតិចិន បង្កើតរោងចក្រ កែច្នៃកៅស៊ូ ៩២០

## ២– ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស

២៨-៥-១៩៩៩ -ប្រកាសលេខ ៥០០ អយក.ប្រក ស្តីពីការបើកសាលាបឋមសិក្សា កុមារពិការ ឡាវ៉ាឡា ៩២២

២៨-៥-១៩៩៩ -ប្រកាសលេខ ៥០១ អយក.ប្រក ស្តីពីការទទួលស្គាល់សាលាបឋមសិក្សា វត្តតាបាង់-តាសរ់ ៩២៣

២៨-៥-១៩៩៩ -ប្រកាសលេខ ៥០២ អយក.ប្រក ស្តីពីការទទួលសាលាបឋមសិក្សា ទួលតាធន់ ៩២៤

២៨-៥-១៩៩៩ -ប្រកាសលេខ ៥០៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ស្វាយអាត់ មកជាសាលាបឋមសិក្សា ឈុនជឹម ស្វាយអាត់ ៩២៦

## ៣– ទីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

### ប្រកាស

២៨-៥-១៩៩៩ -ប្រកាសលេខ ៣១ ប្រក.ស្តីពីការតែងតាំងមន្ត្រីរាជការ ៩២៧

២៨-៥-១៩៩៩ -ប្រកាសលេខ ៣២ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ៩២៨

២៨-៥-១៩៩៩ -ប្រកាសលេខ ៣៤ ប្រក. ស្តីពីការតែងតាំងមន្ត្រីរាជការ ៩២៩

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

## ព្រះរាជក្រម នស/រកម/០៥៩៩/០៣

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ ហើយមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
# ស្តីពី
# ការហាមប្រើប្រាស់គ្រាប់មីន គ្រប់ប្រភេទប្រឆាំងមនុស្ស

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១ .- ច្បាប់នេះ មានគោលដៅហាមឃាត់ការប្រើប្រាស់ ការផលិត ការកាន់កាប់ ការជួញដូរ ការនាំចេញ និងការនាំចូលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ។

មាត្រា ២ .- គ្រាប់មីនប្រឆាំងមនុស្ស គឺគ្រាប់មីនទាំងឡាយដែលធ្វើឡើង ដើម្បីឲ្យផ្ទុះនៅពេលមានវត្តមានមនុស្សក្នុងទីជិត ឬប៉ះ ឬនៅពេលមនុស្សទៅប៉ះបណ្តាលឲ្យមនុស្សម្នាក់ ឬច្រើននាក់ រងរបួស ពិការ ឬស្លាប់ ។

គ្រាប់មីន គឺជាឧបករណ៍ ដែលគេយកទៅកប់ក្នុងដី ឬដាក់លើផ្ទៃដី ឬនៅលើទីដទៃទៀត ហើយដែលផ្ទុះនៅពេលមានវត្តមានឆ្ងាយ ឬជិតនៃមនុស្ស សត្វ ឧបករណ៍ ឬគ្រឿងយន្តទាំងឡាយ ឬផ្ទុះនៅពេលមានមនុស្ស សត្វ ឧបករណ៍ ឬគ្រឿងយន្តទៅប៉ះ ។

មាត្រា ៣ .- ជនស៊ីវិល ភ្នាក់ងាររាជការទាំងអស់ និងកងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាពិសេសកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថជាតិ កងកំលាំងនគរបាលជាតិ ត្រូវហាមឃាត់ប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្សក្នុងគ្រប់កាលៈទេសៈ លើកលែងតែក្នុងករណីប្រើប្រាស់ដើម្បីធ្វើការបណ្តុះបណ្តាលក្លឹកកោត់បោសសំអាតមីន ។

## ជំពូកទី ២
## សមត្ថកិច្ចត្រួតពិនិត្យគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

មាត្រា ៤ .- ការត្រួតពិនិត្យគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ជាសមត្ថកិច្ចរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ។

មាត្រា ៥ .- ក្រៅពីភារកិច្ច ដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១៦ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៥ ភារកិច្ចបន្ថែមរបស់មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាមាន ៖

- ចូលរួមសហការធ្វើអធិការកិច្ចជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធនៅគ្រប់ទីកន្លែង ដែលគេសង្ស័យថាមានការរំលោភលើការហាមឃាត់ តាមការកំណត់ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់នេះ ។

- កំរេចកំទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្សទាំងអស់ ដែលនៅមាន និងរកឃើញ ។
- កំរេចកំទេចចោលគ្រាប់មីនគ្រប់ប្រភេទក្រៅពីគ្រាប់មីនប្រឆាំងមនុស្ស និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងអស់ ដែលនៅមាន និងរកឃើញដោយពុំមានការគ្រប់គ្រង និងថែរក្សាទុកឲ្យអាជ្ញាធរមានសមត្ថកិច្ច ។
- ធ្វើសហប្រតិបត្តិការជាមួយអង្គការបរទេស ដើម្បីទប់ស្កាត់ការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ។
- ទទួលរបាយការណ៍ពីអង្គភាពនានា ស្តីពីការប្រើប្រាស់ដោយគិតទាំងការកាន់កាប់ ការផ្ទេរ ការជួញដូរ ការនាំចេញ ការនាំចូលគ្រាប់មីនគ្រប់ប្រភេទ ហើយរាយការណ៍ជូនរដ្ឋាភិបាល ។
- ទទួលភារកិច្ចធ្វើការគ្រប់គ្រង ត្រួតពិនិត្យ ឬសំរបសំរួលការងារដោះមីន និងកំទេចគ្រឿងផ្ទុះគ្រប់ប្រភេទ នៃអង្គការក្រៅរដ្ឋាភិបាលទាំងឡាយ ដែលកំពុង ឬដែលនឹងមកបំពេញកិច្ចប្រតិបត្តិការបោសសំអាតមីននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។
- ធ្វើសហការជាមួយស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីអនុវត្តសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតុបករណ៍អន្តរជាតិទាំងឡាយក្នុងការបំពេញកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងបញ្ហាមីនប្រឆាំងមនុស្សគ្រប់ប្រភេទ ។

ក្រសួង ឬ ស្ថាប័នដែលត្រូវចូលរួមធ្វើអធិការកិច្ចនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## ទោសប្បញ្ញត្តិ

**មាត្រា ៦ .-** ជនណាកាន់កាប់ ថែរក្សាទុក ដោយចេតនានូវគ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយខែដល់មួយឆ្នាំ និងពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ដល់ប្រាំលាន (៥.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

**មាត្រា ៧ .-** ជនណាប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល ដោយមិនទាន់គិតបញ្ចូលនូវទោសព្រហ្មទណ្ឌធ្ងន់ធ្ងរ ចំពោះបច្ច័យនៃបទល្មើស ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់ជីវិត និងរូបរាងកាយមនុស្ស និងសំណង់រដ្ឋឬឯកជនផ្សេងៗទៀតឡើយ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេរជាពីរ ។

មាត្រា ៨ .- ជនណាផលិត ជួញដូរ នាំចូល ឬនាំចេញ គ្រាប់មីនប្រឆាំងមនុស្ស ទោះជាប្រភេទណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរប្រាំឆ្នាំ ដល់ដប់ឆ្នាំ និងពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ម្ភៃលាន (២០.០០០.០០០)រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេជាពីរ ។

គ្រាប់មីនទាំងឡាយ ដែលបានលើកឡើងក្នុងមាត្រា៦ មាត្រា៧ និងមាត្រា៨ ត្រូវរឹបអូស និងបំផ្លាញចោល ។

មាត្រា ៩ .- បើជនល្មើសជាភ្នាក់ងារ ឬមន្ត្រីនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ឬជាមន្ត្រី នៃអង្គការក្រៅរដ្ឋាភិបាលនានា ដែលប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសកម្មភាពប្រហាក់ប្រហែលនឹងមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាដែរនោះ ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា៦ មាត្រា៧ និងមាត្រា៨ នៃច្បាប់នេះជាអតិបរមា ដោយឥតមានការសំរាលទោសឡើយ ។

## ជំពូកទី ៤

## អន្តរប្បញ្ញត្តិ

មាត្រា ១០.- ជនណា ឬក្រសួងណា ឬស្ថាប័នណាដែលបានកាន់កាប់គ្រាប់មីនប្រឆាំងមនុស្សប្រភេទណាក៏ដោយ ត្រូវធ្វើរបាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ដែលមានកាតព្វកិច្ចធ្វើសេចក្តីរាយការណ៍ជូនមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា បញ្ជាក់អំពីប្រភេទ ចំនួន និងព័តមានពិស្តារផ្សេងៗពាក់ព័ន្ធនឹងគ្រាប់មីន ដែលខ្លួនកំពុងកាន់កាប់ ថែរក្សាទុកក្នុងរយៈពេលកៅសិបថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែលច្បាប់នេះ ចូលជាធរមានប្បញ្ញត្តិ ។

មាត្រា ១១.- មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ត្រូវកំចាត់គ្រាប់មីនប្រឆាំងមនុស្សគ្រប់ប្រភេទទាំងនោះ តាមការកំណត់ដូចមានចែងក្នុងមាត្រា១០ ឲ្យអស់ក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីច្បាប់នេះចូលជាធរមាន រួចហើយត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

មាត្រា ១២.- បទប្បញ្ញត្តិទាំងឡាយណា ដែលពាក់ព័ន្ធនឹងបញ្ហាមីនប្រឆាំងមនុស្ស ហើយដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣.- ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**សុខ អាន**

***

# ព្រះរាជក្រឹត្យ

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៤/៣៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**តែងតាំង**

**លោកអាចារ្យ ហេង គឹមគុណ**

**ជា**

**អ្នកឧកញ៉ា ទទួលកិច្ចការធម្មការក្នុងព្រះបរមរាជវាំង**

ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៤

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

# ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងឯកឧត្តម **ខួន ផនសុីផុន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកកិច្ចការកៅស៊ូ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៦

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៥៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំង ៖

១- ឯកឧត្តម **ម៉ម សារិន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារនយោបាយ មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម **សោម ស៊ឿន** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារទំនាក់ទំនងរវាងគណបក្សនយោបាយនានា មានឋានៈស្មើ **រដ្ឋលេខាធិការ**

៣- ឯកឧត្តម **គាត ស៊ុនអ៊ី** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារច្បាប់ មានឋានៈស្មើ **រដ្ឋលេខាធិការ**

**មាត្រា ២ .-** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

***

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់ប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ .- តែងតាំងមន្ត្រីដឹកនាំខុទ្ទកាល័យផ្ទាល់របស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ដូចតទៅ ៖

| | |
|---|---|
| ១- ឯកឧត្តម **ជា សុន** | ជានាយកខុទ្ទកាល័យ មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ២- លោកជំទាវ **គន្ធាបុប្ផា ម៉ាន់លីរុន** | ជានាយកពិធីការ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ៣- ឯកឧត្តម **សុខ ណោ** | ជានាយករងខុទ្ទកាល័យ ទទួលបន្ទុកការងារនីតិកម្ម មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |
| ៤- ឯកឧត្តម **ប៊ុន ឧត្ដា** | ជានាយករងខុទ្ទកាល័យ ទទួលបន្ទុកការងាររដ្ឋបាល មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** |

មាត្រា ២ .- ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

## ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់ប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៤ ខែមិនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រធានព្រឹទ្ធសភា ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៩

### ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំង ៖

១- លោកឧកញ៉ា ស្រី សុម៉ារ៉ាណ្ណ ជាទីប្រឹក្សាផ្ទាល់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនិរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភាទទួលបន្ទុកទំនាក់ទំនងជំនួយ និងវិទិយោគអន្តរជាតិ មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម តាន់ ហារីស៊ី ជាទីប្រឹក្សាផ្ទាល់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភាទទួលបន្ទុកផ្នែកអភិវឌ្ឍន៍ជនបទ និងពាណិជ្ជកម្ម មានឋានៈស្មើ រដ្ឋលេខាធិការ

៣- ឯកឧត្តម ចាន់ ចំរើន ជាទីប្រឹក្សាផ្ទាល់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភាទទួលបន្ទុកទំនាក់ទំនងទូទៅផ្នែកពាណិជ្ជកម្ម មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម គៀត ទាសនា ជាទីប្រឹក្សាផ្ទាល់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភាទទួលបន្ទុកផ្នែកវិនិយោគជាតិ-អន្តរជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៥- ឯកឧត្តម អ៊ួច ខេង ជាទីប្រឹក្សាផ្ទាល់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភាទទួលបន្ទុកផ្នែកច្បាប់ទូទៅ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៦- ឯកឧត្តម គុជ ស៊ីនិត ជាទីប្រឹក្សាផ្ទាល់ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជីវ័ន្តមុនីរក្ស អនុប្រធានទី១ នៃព្រឹទ្ធសភាទទួលបន្ទុកផ្នែកសំណង់ និងដឹកជញ្ជូន មានឋានៈស្មើ អនុរដ្ឋលេខាធិការ

**មាត្រា ២ .-** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៥៩៩/១១៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងលោកឧត្តម អ៊ុច គឹមអន ជាអ្នកតំណាងផ្ទាល់របស់រាជរដ្ឋាភិបាលកម្ពុជា អមក្រុមប្រឹក្សាអធិរាជ្ញ...ដែលមានការប្រយ័ត្នប្រយែង បន្ថែមលើមុខងារបច្ចុប្បន្ន ជារដ្ឋលេខាធិការ នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

## II- ព្រឹទ្ធសភា

## សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ០០៩/៥៩៩/ពស.សរ

### ស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

* * *

ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការតែងតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ នៃព្រឹទ្ធសភាសំរាប់នីតិកាលទី១

- បានឃើញ ជំពូកទី៥ នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ស្ដីអំពីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ផ្អែកតាមការសំរេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា នាសម័យប្រជុំថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៩

**សំរេច**

ប្រការ ១ : អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាស្ថាប័នមួយឯករាជ្យ អព្យាក្រឹត្យបំពើការងារឲ្យព្រឹទ្ធសភា ហើយស្ថិតក្រោមការដឹកនាំរបស់អគ្គលេខាធិការមួយរូប និង អគ្គលេខាធិការមួយរូបជាជំនួយការ ។

ប្រការ ២ : អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានរចនាសម្ព័ន្ធ ដូចតទៅ ៖

១- ខុទ្ទកាល័យប្រធានព្រឹទ្ធសភា

២- ក្រុមប្រឹក្សាអ្នកច្បាប់

៣- អគ្គាធិការដ្ឋាន

៤- នាយកដ្ឋាន ចំនួន ៣ គឺ ៖

- នាយកដ្ឋានរដ្ឋបាល មាន ៣ការិយាល័យ
- នាយកដ្ឋាននីតិវិធី មាន ៣ការិយាល័យ
- នាយកដ្ឋានហិរញ្ញវត្ថុ មាន ៣ការិយាល័យ

៥- ការិយាល័យ (ចំណុះផ្ទាល់អគ្គលេខាធិការ) ចំនួន ២ គឺ ៖

- ការិយាល័យពិធីការ
- ការិយាល័យបច្ចេកទេស

ប្រការ ៣ : តួនាទី និងភារកិច្ចជាក់ស្ដែងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានចែងនៅក្នុងឧបសម្ព័ន្ធនៃសេចក្ដីសំរេច ។

ប្រការ ៤ : អគ្គលេខាធិការព្រឹទ្ធសភា មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រធានព្រឹទ្ធសភា

ហត្ថលេខា និង ត្រា

**ជា ស៊ីម**

★★★

## រចនាសម្ព័ន្ធគ្រប់គ្រងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា



# III- ក្រុមប្រឹក្សាធម្មនុញ្ញ

## សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ០៧ កបធ.សសរ.ច

***

### ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញ លិខិតប្រធានរដ្ឋសភាលេខ ២៥៣ រស ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួល នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៩
- ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ
- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទមានចែងក្នុងមាត្រា១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យអនុម័តច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខ័ណ្ឌទី២ ក្នុងការបញ្ជូនមកឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើច្បាប់រៀបចំអង្គការនេះ
- យល់ឃើញថា ទំរង់នៃការតាក់តែង និងអនុម័តច្បាប់រៀបចំអង្គការនេះ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃមាត្រា ១,២,៣,៤,៥ និង៦ នៃច្បាប់រៀបចំអង្គការនេះឥតមានកន្លែងណាខុស ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

សំរេច

មាត្រា ១ .- ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៩៩ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២ .- សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរ ពុំទទួលតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ហត្ថលេខា និង ត្រា

**ចាន់ សុខ**

★★★

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩

# សេចក្តីសំរេចលេខ ០៨ កបធ.សសរ.ចរ

***

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញ លិខិតប្រធានរដ្ឋសភាលេខ ២៥៤ រស ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩ ស្នើសុំពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួល នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៩
- ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទមានចែងក្នុងមាត្រា១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញក្នុងការពិនិត្យអនុម័តច្បាប់ ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ កថាខណ្ឌទី២ ក្នុងការបញ្ជូនមកឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុននឹងប្រកាសឲ្យប្រើច្បាប់វេប្រចាំអង្គការនេះ
- យល់ឃើញថា ទំរង់នៃការតាក់តែង និងអនុម័តច្បាប់វេប្រចាំអង្គការនេះ ពុំមានផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃមាត្រា ១,២,៣,៤,៥ និង៦ នៃច្បាប់វេប្រចាំអង្គការនេះគ្មានកន្លែងណាខុស ឬ ផ្ទុយនឹងរដ្ឋធម្មនុញ្ញទេ

**សំរេច**

**មាត្រា ១ .-** ច្បាប់ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយនោះ ត្រូវបានប្រកាសថាស្របទាំងស្រុងនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២ .-** សេចក្ដីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្ដីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ។

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន
បណ្ឌិតសភាចារ្យ ត្រា
**ចាន់ សុខ**

★★★

# IV- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ៩៨ អនក្រ.បក

**កែតំរូវលើអនុក្រឹត្យលេខ ៥១ អនក្រ.បក**

**ស្ដីពី**

**ការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញ តំរូវការចាំបាច់របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**សំរេច**

**មាត្រា ១ .-** មាត្រា១ មាត្រា៧ មាត្រា១៩ មាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ និងមាត្រា២៧ នៃអនុក្រឹត្យ លេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៥ ត្រូវបានកែតំរូវដូចខាងក្រោម ៖

មាត្រា១ ថ្មី ៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ហៅកាត់ថា "ក.អ.ក" មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- | សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- | ឯកឧត្តម គាត ឈន់ ទេសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានទី១ |
| ៣- | ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានទី២ |
| ៤- | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឬតំណាង | សមាជិក |
| ៥- | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬតំណាង | សមាជិក |
| ៦- | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឬតំណាង | សមាជិក |
| ៧- | រដ្ឋមន្ត្រីក្រសួងផែនការ ឬតំណាង | សមាជិក |
| ៨- | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ឬតំណាង | សមាជិក |
| ៩- | រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬតំណាង | សមាជិក |
| ១០- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឬតំណាង | សមាជិក |
| ១១- | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ឬតំណាង | សមាជិក |
| ១២- | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឬតំណាង | សមាជិក |
| ១៣- | រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬតំណាង | សមាជិក |

១៤- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១៥- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍ សមាជិក

១៦- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

មាត្រា១៧ ថ្មី : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានគណៈកម្មាធិការប្រតិបត្តិមួយសំរាប់ដឹកនាំការងារប្រចាំថ្ងៃ ។ គណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានសមាសភាព ដូចតទៅ ៖

១- ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

២- អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៣- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

៤- អគ្គលេខាធិការគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍

៥- អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា

មាត្រា១៩ ថ្មី : ប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទី ដូចតទៅ ៖

- ទទួលខុសត្រូវទូទៅលើការងាររបស់ "ក.អ.ក"
- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក"
- ដឹកនាំ ពិភាក្សា និងថែរក្សាសណ្តាប់ធ្នាប់នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គ "ក.អ.ក"
- ចុះហត្ថលេខាលើកំណត់ហេតុ នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ នៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក"
- កោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងប្រជុំវិសាមញ្ញពេញអង្គរបស់ "ក.អ.ក"
- ទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិការបស់ "ក.អ.ក"

មាត្រា២០ ថ្មី : អនុប្រធាននៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានតួនាទី ដូចតទៅ ៖

**ក/ អនុប្រធានទី ១ :**

១- ទទួលខុសត្រូវទូទៅលើការងាររបស់ "ក.អ.ក" ក្នុងករណីដែលប្រធាន "ក.អ.ក" អវត្តមាន ឬមានជំងឺ

២- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ "ក.អ.ក"

៣- ធ្វើជាអធិបតី នៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" និងអង្គប្រជុំពេញអង្គរបស់ "ក.អ.ក" និងចុះហត្ថលេខាលើកំណត់ហេតុនៃអង្គប្រជុំនោះក្នុងករណី

ដែលប្រធាន “ក.អ.ក” អវត្តមាន ឬជាប់រវល់ភារកិច្ចផ្សេងៗ ឬមានជំងឺមិនអាចចូលរួមប្រជុំបាន

៤- ទទួលបន្ទុកក្នុងការសម្របសម្រួលការងារអន្តរក្រសួងរវាង “ក.អ.ក” ជាមួយនឹងក្រសួង និង/ឬ ស្ថាប័ននានា នៃរាជរដ្ឋាភិបាល

៥- ទទួលបន្ទុកក្នុងការទាក់ទងជាមួយប្រទេស និងអង្គការអន្តរជាតិ អ្នកផ្តល់ជំនួយនានា

៦- ធ្វើជាអធិបតីនៃអង្គប្រជុំរបស់យន្តការ “ច្រកចេញ-ចូលតែមួយ” ដែលរៀបចំឡើងដោយ “ក.អ.ក” ដើម្បីពិនិត្យឯកភាពនៅក្នុងយន្តការ “ច្រកចេញ-ចូលតែមួយ” លើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការងារវិនិយោគនានា មុននឹងដាក់ស្នើសេចក្តីសម្រេចពីអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃ “ក.អ.ក”

៧- បំពេញការងារផ្សេងទៀត ដែលប្រធាន “ក.អ.ក” ប្រគល់ឲ្យ ។

ខ/អនុប្រធានទី២ :

១- ទទួលខុសត្រូវទូទៅលើការងាររបស់ “ក.អ.ក” ក្នុងករណីដែលប្រធាន និងអនុប្រធានទី១ នៃ “ក.អ.ក” អវត្តមាន ឬមានជំងឺ

២- ទទួលខុសត្រូវ និងទទួលបន្ទុកការងារដូចមានចំណាត់ត្រង់ចំណុច ក/២ ក/៣ ក/៤ ក/៥ និងក/៦ នៃមាត្រា២០ថ្មី ខាងលើ ក្នុងករណីដែលអនុប្រធានទី១ អវត្តមាន ឬមានជំងឺ ។

៣- បំពេញការងារផ្សេងទៀតដែលប្រធាន “ក.អ.ក” ប្រគល់ឲ្យ ។

មាត្រា២១ ថ្មី : អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានតួនាទីដូចតទៅ :

- ទទួលបន្ទុកក្នុងការសម្របសម្រួលការងាររបស់គណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍ និងគណៈកម្មាធិការវិនិយោគកម្ពុជា ព្រមទាំងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាន នៃ “ក.អ.ក”
- រៀបចំកម្មវិធីការងាររបស់ “ក.អ.ក” និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗ សំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ “ក.អ.ក” និង សំរាប់អង្គប្រជុំពេញ អង្គរបស់ “ក.អ.ក”
- រៀបចំកំណត់ហេតុនៃអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិនៃ “ក.អ.ក” និងនៃអង្គប្រជុំពេញអង្គរបស់ “ក.អ.ក” ដើម្បីដាក់ជូនប្រធានអង្គប្រជុំចុះហត្ថលេខា
- រៀបចំសេចក្តីប្រកាសព័ត៌មានរបស់ “ក.អ.ក”

- រៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ អំពីការងារនីតិសម្បទា និងអភិវឌ្ឍន៍ និងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន "ក.អ.ក" ពិនិត្យ និងអនុម័តមុននឹងធ្វើជូនរាជរដ្ឋាភិបាល
- ចូលរួមក្នុងអង្គប្រជុំរបស់បន្ទការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសំរេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ និងលើការវិនិយោគនានា
- បំពេញការងារផ្សេងទៀតដែលប្រធាន "ក.អ.ក" ឬ អនុប្រធាន "ក.អ.ក" ប្រគល់ឲ្យ

មាត្រា២២ ថ្មី : អគ្គលេខាធិការរងគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍មានតួនាទី ដូចតទៅ ៖

- គ្រប់គ្រងការងាររបស់ "គ.ជ.អ"
- រៀបចំរបៀបវារៈ និងកត់ការកំណត់អង្គប្រជុំនៃបន្ទការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍
- ជួយលើអគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិននៅនឹងកិច្ចការនីតិសម្បទា និង អភិវឌ្ឍន៍សំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ នៃ "ក.អ.ក" និង សំរាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"
- ធ្វើការតាមដានលើការអនុវត្តន៍កម្មវិធី និងគំរោងវិនិយោគលក្ខណៈផ្សេងៗ ដោយសហការជាមួយមន្ត្រីក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និងលើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតំរូវក្នុងករណីចាំបាច់
- ជួយលើអគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ដើម្បីដាក់ជូន "ក.អ.ក" ពិនិត្យ និងអនុម័តមុននឹងធ្វើជូនរាជរដ្ឋាភិបាល
- ចូលរួមក្នុងអង្គប្រជុំរបស់បន្ទការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសំរេចលើកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍
- បំពេញការងារផ្សេងទៀត ដែលទាក់ទិនទៅនឹងកិច្ចការនីតិសម្បទា និងអភិវឌ្ឍន៍ ស្របតាមការប្រគល់ភារកិច្ចពីប្រធាន "ក.អ.ក" ឬ អនុប្រធាន "ក.អ.ក" ប្រគល់ឲ្យ ។

មាត្រា២៣ ថ្មី : អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា មានតួនាទី ដូចតទៅ ៖

- គ្រប់គ្រងការងាររបស់ "គ.វ.ក"
- រៀបចំរបៀបវារៈ និងឯកសារសំរាប់អង្គប្រជុំនៃយន្តការ "ច្រកចេញ-ចូលតែមួយ" ដែលមានការទាក់ទងទៅនឹងកិច្ចការវិនិយោគឯកជន
- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំសំណុំឯកសារចាំបាច់ ដែលមានការទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន សំរាប់អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ នៃ "ក.អ.ក" និងសំរាប់អង្គប្រជុំពេញអង្គរបស់ "ក.អ.ក"
- ធ្វើការតាមដានលើការអនុវត្តន៍កម្មវិធី និងគំរោងវិនិយោគឯកជនផ្សេងៗ ដោយសហការជាមួយបណ្តាក្រសួង និងស្ថាប័នជំនាញ ដែលមានការពាក់ព័ន្ធ ហើយធ្វើរបាយការណ៍បូកសរុប និង លើកយោបល់ជូនគណៈកម្មាធិការប្រតិបត្តិ នៃ "ក.អ.ក" ដើម្បីពិនិត្យ និងចាត់វិធានការកែតំរូវក្នុងករណីចាំបាច់
- ជួយដល់អគ្គលេខាធិការ "ក.អ.ក" ក្នុងការរៀបចំរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំលើផ្នែកការងារពាក់ព័ន្ធទៅនឹងកិច្ចការវិនិយោគឯកជន ដើម្បីដាក់ជូន "ក.អ.ក" ពិនិត្យ និងអនុម័តមុននឹងធ្វើជូនរាជរដ្ឋាភិបាល
- ចូលរួមក្នុងការអង្គប្រជុំរបស់យន្តការ "ច្រកចេញ-ចូលតែមួយ" ដើម្បីពិនិត្យ និងសំរេចលើកិច្ចការវិនិយោគឯកជន
- បំពេញការងារដទៃទៀត ដែលទាក់ទិនទៅនឹងកិច្ចការវិនិយោគឯកជន ស្របតាមការប្រគល់ភារកិច្ចពីប្រធាន "ក.អ.ក" ឬប្រធាន "ក.អ.ក" ប្រគល់ឲ្យ ។

មាត្រា២៧ ថ្មី : ក្នុងករណីចាំបាច់ប្រធាន "ក.អ.ក" អាចនឹងកោះប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការប្រតិបត្តិនៃ "ក.អ.ក" ឬប្រជុំពេញអង្គវិសាមញ្ញរបស់ "ក.អ.ក" ។

**មាត្រា ២ .-** ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

***

# អនុក្រឹត្យលេខ ១៥០ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- យោងតាមសំណើរបស់ក្រសួងពាណិជ្ជកម្ម

## សំរេច

**មាត្រា ១ .-** តែងតាំងលោក **លីវ មិនចំនួ** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងពាណិជ្ជកម្ម ជាប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងពាណិជ្ជកម្ម ជំនួសអ្នកស្រី **ទ្រឿង សារ៉ាត់** ប្រធាននាយកដ្ឋានរដ្ឋបាល ដែលបានស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរយៈពេលវែង ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

បានចុះហត្ថលេខា និង ត្រា

ហ៊ុន សែន

***

# អនុក្រឹត្យលេខ ១៥១ អនក្រ.តត

## ស្តីពីការជូនមេដាយការងារ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

### សម្រេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសការងារ ជូនលោកវេជ្ជបណ្ឌិត Georg PETERSEN តំណាងអង្គការសុខភាពពិភពលោកប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្ត និងចំណេះដឹងក្នុងការជួយទ្រទ្រង់ ការពារ និងអភិវឌ្ឍន៍ កិច្ចការថែទាំសុខភាពប្រជាពលរដ្ឋកម្ពុជា ចាប់ពីខែឧសភា ឆ្នាំ១៩៩៤ ដល់ខែឧសភា ឆ្នាំ១៩៩៩ ដោយចំណាយអស់ថវិកាជំនួយប្រមាណពី០២ ទៅ ០៤លានដុល្លារអាមេរិកក្នុង មួយឆ្នាំ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យលេខ ១៥២ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញ ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រម ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណៈ និងដឹកជញ្ជូន
- បានឃើញ អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## សំរេច

**មាត្រា ១ .-** តែងតាំងលោក លូ គឹមឈុន ជាអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុសំរាប់អាណត្តិ ០៣ឆ្នាំ ដោយគិតចាប់តាំងពីថ្ងៃដែលសាមីខ្លួនត្រូវបានតែងតាំង ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អភិបាលក្រុងព្រះសីហនុ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឲ្យទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និង ត្រា

ស ខេង

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ៤៤ សសរ
### ស្តីពីការបង្កើតគណៈបញ្ជាការការពារ
### ពិធីកំទេចអាវុធនៅខេត្ត កំពង់ចាម

* * *

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញ សេចក្តីសំរេចលេខ ២៨ សសរ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការដកហូតអាវុធជាតិផ្ទុះគ្រប់ប្រភេទ
- ពិនិត្យសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈបញ្ជាការការពារពិធីកំទេចអាវុធ នៅខេត្តកំពង់ចាម រួមមានសមាសភាព ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម ឯក សំអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម ជៀង អំ | អភិបាលខេត្តកំពង់ចាម | អនុប្រធាន |
| ៣- ឯ.ឧ.ឧ.ទោ ជឿន សុវណ្ណថា | មេបញ្ជាការយោធភូមិភាគទី ២ | សមាជិក |
| ៤- ឯកឧត្តម ខ្វាន់ សៀម | មេបញ្ជាការកងរាជអាវុធហត្ថ ក.យ.ខ.ភ | សមាជិក |
| ៥- ឯកឧត្តម ម៉ិន ស៊ុយ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម យូ ស៊ុនឡុង | ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ | សមាជិក |
| ៧- លោក ឧ. យុន ឈុន្នី | អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់ | សមាជិក |

| | | | |
|---|---|---|---|
| ៨- | លោក ឧ. ម៉ៅ ចន្ទតារា | ប្រធានលេខាធិការអគ្គនាយកនគរបាល | សមាជិក |
| ៩- | លោក ឧ. សុខ ផល | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ | សមាជិក |
| ១០- | លោក ឧ. លូ រ៉ាមីន | ប្រធាននាយកដ្ឋានប្រឆាំងភេរវកម្ម | សមាជិក |
| ១១- | លោក ហ៊ុល ផានី | ប្រធាននាយកដ្ឋានពិធីការ | សមាជិក |
| ១២- | លោក យ៉ាន ពិសិដ្ឋ | | សមាជិក |
| ១៣- | លោក ជុំ សាគន្ធ | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តកំពង់ចាម | សមាជិក |
| ១៤- | លោក ទ៉ា សារិទ្ធ | មេបញ្ជាការកងរាជអាវុធហត្ថខេត្តកំពង់ចាម | សមាជិក |
| ១៥- | លោក វរ. សួន ឈាងលី | ស្នងការនគរបាល ខេត្តកំពង់ចាម | សមាជិក |

**ប្រការ ២ :** គណៈបញ្ជាការការពារពិធីកំទេចអាវុធមានភារកិច្ច ដូចតទៅ ៖

- រៀបចំចាត់ចែងពិធីឲ្យបានសមរម្យ ការពារសុវត្ថិភាពជូនថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ភ្ញៀវកិត្តិយសជាតិនិងអន្តរជាតិ និងមហាជនចូលរួម
- ត្រួតពិនិត្យកុំឲ្យមានគ្រាប់រំសេវសល់ក្នុងអាវុធ ដែលត្រូវកំទេច រក្សាការពារ និងដឹកជញ្ជូនអាវុធ ដែលត្រូវកំទេចទៅដល់កន្លែងប្រារព្ធពិធី
- ចាត់ចែង អញ្ជើញ និងដោះស្រាយមធ្យោបាយដឹកជញ្ជូនភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិពីភ្នំពេញទៅខេត្តកំពង់ចាម
- រៀបចំសណ្តាប់ធ្នាប់សាធារណៈ ចរាចរទាំងនៅខាងក្នុង និងក្រៅបរិវេណកន្លែងប្រារព្ធពិធី
- ការពារសុវត្ថិភាព បង្ការទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលារាល់សកម្មភាពភេរវកម្ម ការបង្កពលាចលផ្សេងៗ ដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សិស្ស និស្សិត និងមហាជនចូលរួម

**ប្រការ ៣ :** ក្នុងករណីចាំបាច់គណៈបញ្ជាការមានសិទ្ធិបង្កើតអនុគណៈបញ្ជាការ ដើម្បីជួយក្នុងការងារនេះ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គបញ្ជាការ ក.យ.ខ.ភ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ គណៈបញ្ជាការឯកភាពខេត្តកំពង់ចាម និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់ចប់ពិធីជាស្ថាពរ ។

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និង ត្រា

ស ខេង

★★★

## ៣-ផែនការណែនាំ

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៩

## ផែនការណែនាំលេខ ០៨ ជ.ក.ណ

### ស្តីពីការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ ក្នុងគម្រប់ព្រះជន្ម ៦៣ យាងចូល ៦៤ ព្រះវស្សា

* * *

### រាជរដ្ឋាភិបាល

ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ ក្នុងគម្រប់ព្រះជន្ម ៦៣ យាងចូល ៦៤ព្រះវស្សា នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៩៩ ខាងមុខនេះ ។

ដើម្បីសំដែងនូវកត្តញ្ញុតាធម៌ តបស្នងព្រះមហាករុណាធិគុណដ៏ខ្ពង់ខ្ពស់ ក្នុងមនោសញ្ចេតនាគោរពស្រឡាញ់ដឹងគុណយ៉ាងជ្រាលជ្រៅ និងដើម្បីចូលរួមអបអរសាទរថ្វាយព្រះពរសព្ទសាធុការបវរអភាប្រសើរ ថ្វាយចំពោះសម្តេចព្រះរាជអគ្គមហេសីជាទីគោរពសក្ការៈ ក្នុងឱកាសព្រះរាជពិធីចំរើនព្រះជន្មរបស់ព្រះអង្គគម្រប់ ៦៣ យាងចូល ៦៤ព្រះវស្សានេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមធ្វើការណែនាំដូចតទៅនេះ ៖

១- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន អង្គភាព រាជធានីភ្នំពេញ សាលាខេត្ត-ក្រុង សាលារៀន រោងចក្រ សហគ្រាស និងគ្រឹស្ថានក្រុមហ៊ុនឯកជន ត្រូវរៀបចំតុបតែងលំអ ទង់ជាតិ ទង់ក្លែប រជា ពាក្យស្លោកតាំងព្រះឆាយាលក្ខណ៍សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** មានតាំងភ្លើងពណ៌ និងមានពាក្យស្លោកថ្វាយព្រះពរ ។

២- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានីភ្នំពេញ និងគ្រប់ខេត្ត-ក្រុង ត្រូវធ្វើលិខិតថ្វាយព្រះពរ ថ្វាយសម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈឲ្យបានមុនថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ និងផ្ញើជូនបណ្តាញសារព័ត៌មានដើម្បីផ្សព្វផ្សាយ ។

៣- ក្រសួងព្រះបរមរាជវាំង ត្រូវចាត់តាំងរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈឲ្យបានសមស្របទៅនឹងប្រពៃណី សាសនា និងប្រពៃណីជាតិ ។

៤- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវធ្វើការណែនាំដល់មន្ទីរវប្បធម៌ខេត្ត-ក្រុង ឲ្យចាត់តាំងសំដែងសិល្បៈជូនមហាជនទស្សនាកំសាន្តនៅតាមទីធ្លាសាធារណៈ នៅថ្ងៃទី ១៨ ខែមិថុនា ឆ្នាំ ១៩៩៩ តាមពេលវេលាសមស្រប ។

៥- ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវមានផែនការណែនាំជាក់ស្តែងដល់អង្គភាពក្រោមឱវាទ គ្រប់ខេត្ត-ក្រុងត្រូវបង្កើនកិច្ចការពារ ថែរក្សាសណ្តាប់ធ្នាប់សង្គម សន្តិសុខ បង្កលក្ខណៈ ជូនប្រជាពលរដ្ឋយើងបានសប្បាយរីករាយ និងធានាសុវត្ថិភាព ។

ទទួលបានផែនការណែនាំនេះ គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានីភ្នំពេញ និងខេត្ត-ក្រុង ត្រូវចាត់តាំងអនុវត្តឲ្យបានទទួលលទ្ធផលល្អប្រសើរ នូវការរៀបចំព្រះរាជពិធីបុណ្យចំរើនព្រះជន្មវស្សា សម្តេចព្រះរាជអគ្គមហេសីជាទីគោរព សក្ការៈ ។

ពាក្យស្លោក :

- សូមថ្វាយព្រះពរ សម្តេចព្រះរាជអគ្គមហេសី ជាទីគោរពសក្ការៈ
- សូមថ្វាយព្រះពរ សម្តេចព្រះរាជអគ្គមហេសី **នរោត្តម មុនីនាថ សីហនុ** សូមមានព្រះជន្មាយុយឺនយូរ
- សូមថ្វាយព្រះពរ បវរមហាប្រសើរ សម្តេចឪ សម្តេចម៉ែ មានព្រះសុខភាពល្អបរិបូរណ៍ និងព្រះជន្មាយុយឺនយូរ

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ស ខេង**

★★★

# V- **ការងារបណ្តាក្រសួង**

## **១-នីតិការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

## **ប្រកាស**

ភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៤៩៩ ឧក.ប្រក**

***

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ លិខិតលេខ ២៦០៧/៩៨ គ.វ.ក ចុះថ្ងៃទី១១-១២-១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញ លិខិតលេខ ៣៥៣ ប.ស្ត ចុះថ្ងៃទី ១៥-០៣-១៩៩៩ របស់ក្រសួងបរិស្ថាន
- បានឃើញ លិខិតលេខ ៦៦៥ ធគស ចុះថ្ងៃទី ០៥-០៣-១៩៩៩ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតឲ្យបើកទីតាំងរោងចក្រកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ៊ីតិច ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី ៣០-០៤-១៩៩៩

**សំរេច**

ប្រការ ១ : អនុញ្ញាតឲ្យក្រុមហ៊ុន ហ៊ីតិច ហ្គាមេន (ខេមបូឌា) (HYTEX GARMENT (CAMBODIA) LTD) តំណាងដោយលោក SAU KIM HING សញ្ជាតិ ម៉ាឡេស៊ី ភេទប្រុស អាយុ ៥១ឆ្នាំ អាស័យដ្ឋាន Lot 25,Jalan E1/5 Kawasan Perindustrian, Taman Ehsan, Peti Sarat 6 Kepong, 52100 Kuala Lumpur MALAYSIA កាន់លិខិតឆ្លងដែនលេខ A9089492 ចុះថ្ងៃទី ២៨-១០-១៩៩៨ បង្កើត "រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ" ដែលមានឈ្មោះថា "រោងចក្រកាត់ដេរ ហ៊ីតិច ហ្គាមេន (ខេមបូឌា)" មានទីតាំងស្ថិតនៅអគារលេខ ៥៣៦ ផ្លូវជាតិលេខ ២ ភូមិព្រៃតាគង់ សង្កាត់ចាក់អង្រែលើ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការសាងសង់ និងរៀបចំគ្រឿងចក្ររបស់ក្រុមហ៊ុន ត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានសំរេចក្នុងរយៈពេល ០៣ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតឲ្យ "កាត់-ដេរ សំលៀកបំពាក់" ទៅតាមគំរូដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្រផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន រ៉ើតិច ហ្គាមេន (ខេមបូឌា) ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះ មានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**

***

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៥០៣ ឧក.ប្រក

***

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញ លិខិតលេខ ១៣៣/៩៨ ក.អ.ក ចុះថ្ងៃទី ២២-០១-១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញ លិខិតលេខ ៥៣១ ស្ហន/៥៦២ កសក.ជ.ផក ចុះថ្ងៃទី ២៧-១១-១៩៩៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការអនុញ្ញាតឲ្យបង្កើតរោងចក្រកែច្នៃឈើបានមកពីការរានដី
- បានឃើញ លិខិតលេខ ០០៩៤ សរសណ របស់សាលាខេត្តកំពង់ស្ពឺ ស្តីពីការអនុញ្ញាតឲ្យបើកទីតាំងសាងសង់រោងចក្រកែច្នៃកសិផល និងឈើដែលបានមកពីការរានដី
- យោងតាមពាក្យស្នើរបស់ក្រុមហ៊ុន ខេមបូឌា ម៉ៃននីង គ្រុប ចុះថ្ងៃទី ៣០-០៣-១៩៩៩

## សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន ខេមបូឌា ហៃនីង គ្រុប (CAMBIDIA HANING GROUP CO., LTD) តំណាងដោយលោក YANG ZHAOFU សញ្ជាតិចិន ភេទប្រុស អាយុ៥១ឆ្នាំ អាស័យដ្ឋាន Beihai Boulevard, Beihai, Guangxi, CHINA 536005 កាន់លិខិតឆ្លងដែនលេខ P 2223605 ចុះថ្ងៃទី 01-09-1999 បង្កើត "រោងចក្រកែច្នៃកសិផល" ដែលមានឈ្មោះថា "រោងចក្រខេមបូឌា ហៃនីង គ្រុប" មានទីតាំងស្ថិតនៅចំណុច F តាមផែនទីកិច្ចព្រមព្រៀងដីសម្បទានជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចុះថ្ងៃទី ២៣-០៧-១៩៩៨ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**ប្រការ ២ :** ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើការទៅតាមប្លង់ ដែលមានការឯកភាពពីអាជ្ញាធរដែនដី និងតំណាងសិក្សាសមិទ្ធិលទ្ធភាពបង្កើតរោងចក្រកែច្នៃកសិផល និងឈើដែលបានមកពីការរានដីសំរាប់ដំណាំឧស្សាហកម្ម ។

**ប្រការ ៣ :** ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

**ប្រការ ៤ :** រោងចក្រនេះ ត្រូវបានអនុញ្ញាតជាសារវន្ត "កែច្នៃកសិផល" និងជាបន្ទាប់បន្សំ "កែច្នៃឈើដែលបានមកពីការរានដី" សំរាប់ដំណាំឧស្សាហកម្ម ។

**ប្រការ ៥ :** រាល់វត្ថុធាតុដើម ដែលមកពីការរានដី ត្រូវមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវបើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តកំពង់ស្ពឺ និងប្រធានក្រុមហ៊ុនខេមបូឌា ហៃនីង គ្រុប ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**

★★★

# ២-នីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាស

ភ្នំពេញ, ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៩

### ប្រកាសលេខ ៤០០ អយក.ប្រក

### ស្តីពីការបើកសាលាបឋមសិក្សា "កុមារពិការ ឡាវ៉ាឡា"

***

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់លោក Terry Heinrich ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៨ ដោយមានចំណារឯកភាពរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

#### សម្រេច

**ប្រការ ១ :** បើកសាលាបឋមសិក្សាចំណេះទូទៅឯកជន កុមារពិការ ឡាវ៉ាឡា ដែលមានទីតាំងស្ថិតនៅផ្លូវ៤៣០ សង្កាត់ទួលទំពូង II ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ១៩៩៨-១៩៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សាចំណេះទូទៅ ឯកជន កុមារពិការ ឡាវ៉ាឡា ត្រូវនៅក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ និងត្រូវអនុវត្តកម្មវិធីសិក្សា តាមការអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៣ : លោក Terry Heinrich ត្រូវដឹកនាំ គ្រប់គ្រង ចាត់តាំងគណៈគ្រប់គ្រងសាលាវៀន និងគ្រូបង្រៀន ដែលមានសមត្ថភាពតរុកោសល្យសមស្រប ព្រមទាំងអនុវត្តឲ្យបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៤ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និងអគ្គាធិការដ្ឋាន នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ការិយាល័យអប់រំ យុវជន និងកីឡា ខ័ណ្ឌចំការមន នាយកសាលាបឋមសិក្សាចំណេះទូទៅរីករាយ កុមារពិការ ឡាវ៉ាឡា និងលោក Terry Heinrich មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៤០១ អយក.ប្រក

## ស្តីពីការទទួលស្គាល់សាលាបឋមសិក្សា វត្តតាហង់ចាស់

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៩

- តាមសេចក្តីស្នើរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ទទួលស្គាល់សាលាបឋមសិក្សា វត្តតាហេង់ចាស់ ដែលមានទីតាំងស្ថិតនៅឃុំ ចំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ១៩៩៨-៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា វត្តតាហេង់ចាស់ ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌសំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ការិយាល័យអប់រំ យុវជន និងកីឡា ស្រុករមាសហែក នាយកសាលាបឋមសិក្សា វត្តតាហេង់ចាស់ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

បណ្ឌិតសាស្ត្រាចារ្យ ... (ហត្ថលេខា និង ត្រា)

**អ៊ឹម សិទ្ធី**

★★★

ភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៨០២ អយក.ប្រក

## ស្តីពីការទទួលស្គាល់សាលាបឋមសិក្សា ទួលតាធន់

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលើលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៩៩
- តាមសេចក្ដីឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

**សំរេច**

**ប្រការ ១ :** ទទួលស្គាល់សាលាបឋមសិក្សា ទួលតាធន់ ដែលមានទីតាំងស្ថិតនៅ ឃុំអណ្ដូងពោធិ៍ ស្រុករមាសហែក ខេត្តស្វាយរៀង ជាសាលាបឋមសិក្សាពេញលក្ខណៈ ចាប់ពីឆ្នាំសិក្សា ១៩៩៨-៩៩ នេះតទៅ ។

**ប្រការ ២ :** សាលាបឋមសិក្សា ទួលតាធន់ត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗស្របតាមបទដ្ឋានប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ ៣ :** នាយក នាយករង មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍កំណត់របស់រដ្ឋ ។

**ប្រការ ៤ :** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥ :** នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ការិយាល័យ អប់រំ យុវជន និងកីឡា ស្រុករមាសហែក នាយកសាលាបឋមសិក្សាទួលតាធន់ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**អ៊ឹម សិទ្ធី**

★★★

ភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៤០៣ អយក.ប្រក**

**ស្តីពីការប្តូរឈ្មោះសាលាបឋមសិក្សា ស្វាយអាត់**

**មកជាសាលាបឋមសិក្សា ឈុន ជឹម ស្វាយអាត់**

***

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១២៩៨/៨៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ
- បានពិនិត្យលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ស្រុកព្រៃវែង ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៩៩
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា

**សំរេច**

ប្រការ ១ : ប្តូរឈ្មោះសាលាបឋមសិក្សា ស្វាយអាត់ ដែលមានទីតាំងស្ថិតនៅ ឃុំជ្រៃ ស្រុកព្រៃវែង ខេត្តព្រៃវែង មកជាសាលាបឋមសិក្សា “ឈុន ជឹម ស្វាយអាត់” ចាប់ពីឆ្នាំសិក្សា ១៩៩៨-៩៩ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តព្រៃវែង ការិយាល័យអប់រំ យុវជន និងកីឡា ស្រុកព្រៃវែង នាយកសាលាបឋមសិក្សា ឈុន ជឹម

ស្ថាប័នអាត់ មានភារកិច្ចអនុវត្តប្រកាសនេះ ។

ជ.ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ឹម សិទ្ធី

★★★

## ៣-នីស្តីការរដ្ឋមន្ត្រីក្រសួងទេសចរណ៍

## ប្រកាស

ភ្នំពេញ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៣១ ប្រក**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

***

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍
- ផ្អែកតាមតម្រូវការចាំបាច់ នៃការអភិវឌ្ឍន៍វិស័យទេសចរណ៍

**សំរេច**

**ប្រការ ១ :** ត្រូវបានតែងតាំងលោកជទាវ ប៉ាន់ ចំណាន ជានាយកខុទ្ទកាល័យ នៃក្រសួងទេសចរណ៍ ។

ប្រការ ២ : អគ្គនាយក នៃអគ្គនាយកដ្ឋានទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ អធិការ ប្រធានមន្ទីរទេសចរណ៍ខេត្ត-ក្រុង និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**វ៉េង សេរីវុឌ្ឍ**

★★★

ភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៣២ ប្រក

## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទេសចរណ៍
- ផ្អែកតាមតម្រូវការចាំបាច់ នៃការអភិវឌ្ឍន៍វិស័យទេសចរណ៍

**សំរេច**

ប្រការ ១ : ត្រូវបានតែងតាំងលោក ឆៃ គឹមហុង ជានាយកខុទ្ទកាល័យ នៃក្រសួងទេសចរណ៍ ។

**ប្រការ ២ :** អគ្គនាយក នៃអគ្គនាយកដ្ឋានទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ អធិការ ប្រធានទេសចរណ៍ខេត្ត-ក្រុង និងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**វ៉េង សេរីវុឌ្ឍ**

★★★

ភ្នំពេញ ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩

## ប្រកាសលេខ ៣៨ ប្រក
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ របស់ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- ផ្អែកតាមតម្រូវការចាំបាច់នៃការអភិវឌ្ឍវិស័យទេសចរណ៍

## សម្រេច

**ប្រការ ១ :** ត្រូវបានតែងតាំងលោកស្រី **ចាយ សុវណ្ណនី** ជាលេខាឯកឧត្តម រដ្ឋមន្ត្រី មានឋានៈស្មើនាយកការិយាល័យ ។

ប្រការ ២ : អគ្គនាយក នៃអគ្គនាយកដ្ឋានទេសចរណ៍ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ អធិការ ប្រធានមន្ទីរទេសចរណ៍ខេត្ត-ក្រុង និងសាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**វេង សេរីវុឌ្ឍ**

★★★